រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ១៣ អនក្រ.បក**

**ស្តីពីវិសោធនកម្មមាត្រា ២ នៃអនុក្រឹត្យលេខ ៤៧ អនក្រ**
**ស្តីពីការបង្កើតគណៈកម្មការ ពិនិត្យប្រៀបធៀបសំណើ**
**និងគំរោងការសាងសង់លើដីកម្មសិទ្ធិរបស់ព្រះរាជាណាចក្រ**
**កម្ពុជានៅបរទេស**

* * * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- តាមព្រះរាជយោបល់សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ និងយោបល់សម្តេចនាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី ២៧ និង ២៩ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ស្តីពីការបង្កើតគណៈកម្មការ ពិនិត្យប្រៀបធៀបសំណើ និង គំរោងការសាងសង់លើដីកម្មសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជានៅបរទេស
- តាមតំរូវការនៃការងារ

**សំរេច**

**មាត្រា ១** : មាត្រា ២ នៃអនុក្រឹត្យលេខ ៤៧ អនក្រ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពី ការបង្កើតគណៈកម្មការ ពិនិត្យប្រៀបធៀបសំណើ និង គំរោងការសាងសង់លើដីកម្មសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវបានកែប្រែដូចតទៅនេះ ៖

**មាត្រា ២ ថ្មី** : គណៈកម្មការនេះមានភារកិច្ចប្រកាសផ្សាយដំណឹង ដល់ក្រុមហ៊ុនវិនិយោគនានា ព្រមទាំងប្រមូលសំណើរបស់ក្រុមហ៊ុនទាំងនោះក្នុងការទិញដូរ ឬ ធ្វើសំណង់លើដីធ្លី

ដែលជាកម្មសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជានៅបរទេស ដើម្បីយកមកប្រៀបធៀប និងស្នើជាយោបល់ថ្វាយ និងជូននាយករដ្ឋមន្ត្រីសំរេច ។

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| --- | --- |
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២[illegible]

**អនុក្រឹត្យលេខ ០៦ អនក្រ.តត**

**ស្តីពីការតែងតាំងផ្លាស់ប្តូរមុខតំណែងកែសម្រួល**

**និងតំលើងឋានន្តរសក្តិ**

* * * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា